ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣១៥,៣៦ ហិកតា នៅក្នុង ស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិង របស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ០១៤ ស.ណ ចុះថ្ងៃទី៣១ខែមករាឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីទំហំ ៣១៥,៣៦ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ទំហំ ២៥៦,៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងរក្សាទុក ទំហំ ៥៨,៤១ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅឃុំ សំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៥២,៥៧ ហិកតាកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៤៩,៨៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ២,៦៨ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិ ក្របីព្រៃ
- ផ្ទៃដីទំហំ ៩៦,៥៤ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៥០,២៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៤៦,៣០ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិប៉ែនមាស



www.pheakdeylaw.com

- ផ្ទៃដីទំហំ ៨៦,៩៦ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៨២,៥០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៤,៤៦ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាស្នន់
- ផ្ទៃដីទំហំ ៣៦,៦៦ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៣៥,៨៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ០,៧៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិ ព្រៃតាដុក
- ផ្ទៃដីទំហំ ៤២,៦៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៣៨,៤៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៤,១៨ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិ ត្រពាំងថ្ម

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៧៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំសំរោង ស្រុក ត្រាំកក់ ខេត្តតាកែវ ក្នុងភូមិ ដូចខាងក្រោម ៖

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧ គ្រួសារ នៅភូមិក្របីព្រៃ
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨២ គ្រួសារ នៅភូមិប៉ែនមាស
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១២ គ្រួសារ នៅភូមិតាស្នន់
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧ គ្រួសារ នៅភូមិព្រៃតាដុក
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧១ គ្រួសារ នៅភូមិត្រពាំងថ្ម ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ......នៃអនុក្រឹត្យលេខ ៣៦ អនក.បក. ចុះថ្ងៃទី.២៦....ខែ.កុម្ភៈ....ឆ្នាំ២០១៣ ស្តីពីការដកហូតកាត់ដីចេញពីគម្របព្រៃឈើឆ្នាំ២០០២
នៅឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ទំហំផ្ទៃដីសរុប ៣០៥.៣៦ ហិកតា ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបាន
កាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងលើផ្ទៃដីទំហំ ២៥៦.៩៥ ហិកតា និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋលើផ្ទៃដីទំហំ ៤៨.៤១ ហិកតា




ចំណុចនិយាមកា
Projection UTM Zone 48N Datum WGS 84

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 451482 | 1212983 | 46 | 450748 | 1214478 |
| 2 | 451499 | 1212861 | 47 | 450750 | 1214525 |
| 3 | 451369 | 1212826 | 48 | 450683 | 1214502 |
| 4 | 451367 | 1212888 | 49 | 450666 | 1214726 |
| 5 | 451275 | 1212874 | 50 | 450609 | 1214728 |
| 6 | 451272 | 1212836 | 51 | 450604 | 1214853 |
| 7 | 451182 | 1212823 | 52 | 450591 | 1214853 |
| 8 | 451118 | 1212775 | 53 | 450595 | 1214873 |
| 9 | 451113 | 1212795 | 54 | 450635 | 1214894 |
| 10 | 451033 | 1212794 | 55 | 450604 | 1214931 |
| 11 | 451030 | 1212752 | 56 | 450552 | 1214972 |
| 12 | 450994 | 1212750 | 57 | 450542 | 1215020 |
| 13 | 450999 | 1212763 | 58 | 450493 | 1215012 |
| 14 | 450941 | 1212764 | 59 | 450486 | 1215119 |
| 15 | 450939 | 1212810 | 60 | 450513 | 1215127 |
| 16 | 450959 | 1212813 | 61 | 450503 | 1215249 |
| 17 | 450955 | 1213006 | 62 | 450561 | 1215268 |
| 18 | 450968 | 1213017 | 63 | 450646 | 1215286 |
| 19 | 450929 | 1213204 | 64 | 450637 | 1215335 |
| 20 | 450941 | 1213279 | 65 | 450606 | 1215363 |
| 21 | 450917 | 1213277 | 66 | 450509 | 1215352 |
| 22 | 450908 | 1213348 | 67 | 450497 | 1215455 |
| 23 | 450831 | 1213341 | 38 | 450577 | 1215479 |
| 24 | 450812 | 1213360 | 69 | 450580 | 1215513 |
| 25 | 450815 | 1213497 | 70 | 450611 | 1215514 |
| 26 | 450791 | 1213508 | 71 | 450609 | 1215536 |
| 27 | 450720 | 1213503 | 72 | 450562 | 1215534 |
| 28 | 450714 | 1213545 | 73 | 450567 | 1215591 |
| 29 | 450769 | 1213616 | 74 | 450701 | 1215599 |
| 30 | 450793 | 1213612 | 75 | 450831 | 1215601 |
| 31 | 450789 | 1213625 | 76 | 450903 | 1215522 |
| 32 | 450767 | 1213623 | 77 | 450936 | 1215517 |
| 33 | 450752 | 1213647 | 78 | 450953 | 1215545 |
| 34 | 450766 | 1213732 | 79 | 451179 | 1215564 |
| 35 | 450733 | 1213734 | 80 | 451308 | 1215600 |
| 36 | 450699 | 1213887 | 81 | 451451 | 1215625 |
| 37 | 450706 | 1214009 | 82 | 451590 | 1215374 |
| 38 | 450886 | 1214045 | 83 | 451690 | 1215227 |
| 39 | 450923 | 1214117 | 84 | 451735 | 1215138 |
| 40 | 450886 | 1214107 | 85 | 451803 | 1215041 |
| 41 | 450888 | 1214164 | 86 | 451843 | 1214883 |
| 42 | 450853 | 1214186 | 87 | 451966 | 1214153 |
| 43 | 450835 | 1214296 | 88 | 452164 | 1213059 |
| 44 | 450880 | 1214307 | 89 | 451752 | 1212990 |
| 45 | 450899 | 1214431 | | | |

ផ្ទៃដីសរុបទំហំ ៣១៥.៣៦ហិចតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ក្នុងនោះផ្ទៃដីទំហំ ២៥៦.៩៥ហិកតា ស្នើសុំធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង ការធ្វើប្រទានកម្ម ជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ជាក់ស្តែង ចំនួន ៣៧៩គ្រួសា និង រក្សាទុកទំហំ ៥៨.៤១ហិចតា ស្ថិតនៅភូមិព្រៃបីព្រៃ ភូមិប៉ែនមាស ភូមិតាសួន ភូមិព្រៃតាមុក ភូមិក្រាំងថ្ម ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ




**ចំណុចនិយាមកា**

Projection UTM Zone 48N.Datum WGS 84

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 451482 | 1212983 | 46 | 450748 | 1214478 |
| 2 | 451499 | 1212861 | 47 | 450750 | 1214525 |
| 3 | 451369 | 1212826 | 48 | 450683 | 1214502 |
| 4 | 451367 | 1212888 | 49 | 450668 | 1214726 |
| 5 | 451275 | 1212874 | 50 | 450609 | 1214728 |
| 6 | 451272 | 1212836 | 51 | 450604 | 1214853 |
| 7 | 451182 | 1212823 | 52 | 450591 | 1214853 |
| 8 | 451118 | 1212775 | 53 | 450595 | 1214873 |
| 9 | 451113 | 1212795 | 54 | 450635 | 1214894 |
| 10 | 451033 | 1212794 | 55 | 450604 | 1214931 |
| 11 | 451030 | 1212752 | 56 | 450552 | 1214972 |
| 12 | 450994 | 1212750 | 57 | 450542 | 1215020 |
| 13 | 450999 | 1212763 | 58 | 450493 | 1215012 |
| 14 | 450941 | 1212764 | 59 | 450488 | 1215119 |
| 15 | 450939 | 1212810 | 60 | 450513 | 1215127 |
| 16 | 450959 | 1212813 | 61 | 450503 | 1215249 |
| 17 | 450955 | 1213006 | 62 | 450561 | 1215268 |
| 18 | 450968 | 1213017 | 63 | 450646 | 1215286 |
| 19 | 450929 | 1213204 | 64 | 450637 | 1215335 |
| 20 | 450941 | 1213279 | 65 | 450606 | 1215363 |
| 21 | 450917 | 1213277 | 66 | 450509 | 1215352 |
| 22 | 450908 | 1213348 | 67 | 450497 | 1215455 |
| 23 | 450831 | 1213341 | 68 | 450577 | 1215479 |
| 24 | 450812 | 1213360 | 69 | 450580 | 1215513 |
| 25 | 450815 | 1213497 | 70 | 450611 | 1215514 |
| 26 | 450791 | 1213508 | 71 | 450609 | 1215536 |
| 27 | 450720 | 1213503 | 72 | 450562 | 1215534 |
| 28 | 450714 | 1213545 | 73 | 450567 | 1215591 |
| 29 | 450769 | 1213616 | 74 | 450701 | 1215599 |
| 30 | 450793 | 1213612 | 75 | 450831 | 1215601 |
| 31 | 450789 | 1213625 | 76 | 450903 | 1215522 |
| 32 | 450767 | 1213623 | 77 | 450936 | 1215517 |
| 33 | 450752 | 1213647 | 78 | 450953 | 1215545 |
| 34 | 450766 | 1213732 | 79 | 451179 | 1215564 |
| 35 | 450733 | 1213734 | 80 | 451308 | 1215600 |
| 36 | 450699 | 1213887 | 81 | 451451 | 1215625 |
| 37 | 450708 | 1214009 | 82 | 451590 | 1215374 |
| 38 | 450886 | 1214045 | 83 | 451690 | 1215227 |
| 39 | 450923 | 1214117 | 84 | 451735 | 1215138 |
| 40 | 450886 | 1214107 | 85 | 451803 | 1215041 |
| 41 | 450888 | 1214164 | 86 | 451843 | 1214883 |
| 42 | 450853 | 1214188 | 87 | 451966 | 1214153 |
| 43 | 450835 | 1214296 | 88 | 452164 | 1213059 |
| 44 | 450880 | 1214307 | 89 | 451752 | 1212990 |
| 45 | 450899 | 1214431 | | | |

**សញ្ញាសម្គាល់**

ចំណុចតំបន់
ភូមិ
សាលារៀន
អាងស្តុកទឹក
ព្រំតំបន់ដីស្នើសុំ
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវក្រាលកៅស៊ូ
ផ្លូវរទេះឬផ្លូវលំ
ទំនប់

**ប្រភេទនៃការប្រើប្រាស់ដី**

ព្រៃស្រោង
ស្រែវស្សា
ដីស្រែជាមួយភូមិ
ចំការដំណាំ
ព្រៃរបោះ
ចំការបោះបង់ដុះស្មៅ
ព្រៃគុម្ពោត
ចំការបោះបង់ដុះព្រៃគុម្ពោត

Coordinate System
Projection: UTM
Zone: 48N
Map Datum: WGS84

មាត្រដ្ឋាន:1:20,000

0 ១០០០ ម